ព្រឹត្តិបត្រ ប្រចាំខែ

# អ្នកនាំសារ THE MESSENGER

ពត៌មានពីព្រះសហគមន៍កាតូលិក | Internal Use | ឆ្នាំទី ០២ លេខ ១៣ ខែ ឧសភា ឆ្នាំ ២០០៤

## ដីមរណៈសាក្សី ឬ ដី នៃក្ដីសង្ឃឹម

នៅឆ្នាំ២០០០ នៅថ្ងៃទី ៧ ខែ ឧសភា សកលលោកបានប្រារព្ធ ពិធីគោរពមរណៈសាក្សី ដើម្បីរំឭកការពលីជីវិតរបស់ជនទាំងឡាយ ដើម្បីជំនឿ ។ នៅទីក្រុងរ៉ូម សម្ដេចប៉ាបបានប្រារព្ធពិធីនេះ នៅវាលកូលីសេជាទីកន្លែងដែលគ្រិស្ដបរិស័ទរាប់ម៉ឺននាក់នៅសតវត្សទី១ត្រូវគេកាប់សម្លាប់ ដោយបោះទៅឱ្យសត្វខ្លាស៊ីធ្វើចំណី ឬកាប់នឹងដាវ ។ ពិធីនេះ នឹងត្រូវធ្វើម្ដងទៀតទូទាំងសកលលោក នៅឆ្នាំ២០៥០(ខួបវាគឺ ៥០ឆ្នាំម្ដង) ។

តាំងពីឆ្នាំ ១៩៧០ តទៅទំព័រទី ៣

## ព្រះបន្ទូលផ្ដល់ជីវិត

ព្រះជាម្ចាស់ មានព្រះបន្ទូលទៅកាន់សាវ័កថាៈ "ក្នុងចំណោមអ្នករាល់គ្នា អ្នកដែលធំជាងគេ ត្រូវធ្វើតូចជាងគេ ហើយអ្នកដែលដឹកនាំគេ ត្រូវបម្រើគេវិញ" លូកា ២២. ២៦ ។

នេះ មិនមែនជាលើកទីមួយទេ ដែលសន្ដលូកាបង្ហាញអំពីពួកសាវ័កជជែកទាស់ទែងគ្នាចង់ដឹងថាៈក្នុងចំណោមពួកគេ អ្នកណាដែលមានឋានៈធំជាងគេ ។ ពេលនោះ គឺជាពិធីជប់លៀងសាវ័ក ជាលើកចុងក្រោយបង្អស់មុនពេលព្រះយេស៊ូត្រូវទទួលរងទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាង។ ក្នុងពិធីជប់លៀងនេះព្រះយេស៊ូបានមានតែងតាំងអគ្គសញ្ញាព្រះកាយ និងព្រះលោហិត ជាសញ្ញានៃសេចក្ដីស្រឡាញ់ ...

តទៅទំព័រទី ៤

# ពិធីច្រត់ព្រះនង្គ័ល



ពិធីច្រត់ព្រះនង្គ័ល ២០០៤

Photo Pascal

ទំនៀមច្រត់ព្រះនង្គ័ល តែងប្រារព្ធនៅខែពិសាខ។ ខែពិសាខ គឺជាខែដើមឆ្នាំនៅរដូវវស្សា ដែលប្រជារាស្ដ្រខ្មែរត្រូវប្រុងប្រៀបធ្វើស្រែ។ ម្យ៉ាងទៀត ទំនៀមរបស់ខ្មែរមុននឹងចេញដំណើរទៅប្រកបរបរជួញប្រែ ឬទៅជួបទំនាក់ទំនងនរណាម្នាក់ក្នុងការងារធំៗ ឬត្រូវបំពេញកិច្ចការមួយសំខាន់ តែងរើសរកមើលពេលាល្អ តាមក្បួនតម្រា ។ មានការងារខ្លះគេត្រូវរៀបចំពិធី បួងសួងប្រកាសអស់វត្ថុស័ក្ដសិទ្ធិទៀត ដើម្បីជួយឱ្យបានសមតាមបំណងប្រាថ្នា ។ ហេតុដូច្នេះហើយ បានជាត្រូវមានព្រះរាជពិធីច្រត់ព្រះនង្គ័ល។

ព្រះមហាក្សត្រ ទ្រង់ជាស្ដេចដែលមាននាទីគ្រប់គ្រងប្រទេសជាតិ និងប្រជារាស្ដ្រ។ ព្រះអង្គជាព្រះតំណាងឱ្យម្ចាស់ស្រែទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ព្រះអង្គ មានបុណ្យបារមីខ្ពស់ កាលបើស្ដេចយាងចេញច្រត់ព្រះនង្គ័លហើយ នោះច្បាស់ជារំជួលដល់ វរុណហកទេវបុត្រ ដែលជាទេវតាប្រចាំភ្លៀង ។ ម្យ៉ាងទៀត មុននិងច្រត់គឺមុនថ្ងៃមួយរោចខែ

តទៅទំព័រទី ២

## ទិវាពលកម្មអន្ដរជាតិ

ទិវាពលកម្មអន្ដរជាតិ " ឬពាក្យ សាមញ្ញហៅថាៈ បុណ្យការងារដែលពិភពលោកទាំងមូលសន្មត យកជារៀងរាល់ឆ្នាំ ថ្ងៃទី១ ឧសភា ជាថ្ងៃរំឭក ដល់ការតស៊ូដើម្បីរំដោះប្រជាពល ករចេញពីការងារដ៏ធ្ងន់ធ្ងរ។ ខាងក្រោមនេះ ជាប្រវត្តិសង្ខេបទិវាពលកម្ម

តទៅទំព័រ ទី ៥

# ពិធីច្រត់ព្រះនង្គ័ល



កសិករដែលចូលរួមពិធី

ពិសាខ ចៅភ្នាក់ងារក្រុមមេការ ត្រូវធ្វើរោងប្រាំ សម្រាប់តាំងពិធីនៅទីព្រះស្រែ (វាលព្រះមេរុខាងជើងព្រះរាជវាំង)។ ភ្លេងពិណពាទ្យ លេងកំដរបទបួងសួង និងសាធុការ ។ លុះដល់ថ្ងៃ មួយរោច ខែពិសាខ ក្រុមព្រាហ្មណ៍បុរោហិតត្រូវទៅធ្វើហោមពិធីក្នុងមណ្ឌលទាំងប្រាំនោះ តាមក្បួនព្រាហ្មណ៍ ។ រោងទាំង ប្រាំនោះ សង់នៅទិស បូព អាគ្នេយ៍ និរតី ពាយព្យ និង ឦសាន ។

កាលបើ ធ្វើហោមពិធីគ្រប់ បីថ្ងៃ ហើយ វេលាព្រឹកព្រះកុណាស្ដេចយាង ចេញច្រត់ព្រះនង្គ័ល ដើម្បីជាសិរីមង្គល ដល់ការធ្វើស្រែរបស់រាស្ត្រ ។ ប្រសិនបើ ព្រះអង្គមិនយាងចេញទេ ព្រះអង្គចាត់អ្នកជំនួសក្នុងការនេះ។ ព្រះរាជតំណាងនោះ ទោះបីមិនមែនជាស្ដេច ក៏ត្រូវហៅថា "ស្ដេចមាយ[១]" ដែរ។ ឯភរិយាសន្មតថាជាព្រះទេពី ហៅថា"ព្រះមេហួ[២] "។ កាធ្វើបែបនេះ ដើម្បីឱ្យមានបុណ្យបារមីខ្ពស់និងឱ្យស័ក្តិសិទ្ធ ដូចបានពោលខាងលើ ។ ស្ដេចមាយ និងព្រះមេហួ តែងខ្លួនតាមរបៀបក្សត្រ ដោយស្ដេចមាយគង់លើព្រះសាលៀង ព្រះមេហួគង់អង្រឹងស្នែងហែហមដោយក្បួនមនុស្សប្រហែលហាសិបនាក់។ ភ្លេងពិណពាទ្យហែនាំមុខដោយប្រគុំបទក្លុំ ។ តែ មុននឹងដំណើរការពិធីច្រត់ព្រះនង្គ័ល ស្ដេចមាយ និងព្រះមេហួ ត្រូវចូលទៅថ្វាយបង្គំរោងមណ្ឌលទិសនិរតី ។ ពិធីច្រត់ព្រះនង្គ័លនេះ មាននង្គ័លបីគឺ នង្គ័លមុខមួយ ហៅថានង្គ័លយោង ឯស្ដេចមាយ កាន់នង្គ័លកណ្ដាល និងមាននង្គ័លដើរតាមក្រោយមួយ ។ ចំណែក ព្រះមេហួ ដើរតាមក្រោយ នង្គ័លទីបី ចាប់ស្រូវពូជនៅក្នុងល្អីដែលមានស្ត្រីម្នាក់កណ្ដៀតបាចទៅឆ្វេង បាចទៅស្ដាំ ។ ក្នុងពេលហែភ្ជួរនេះ ភ្លេងកំដរបទក្លុំដដែល។ ក្បួនហែបានគ្រប់ជុំព្រះស្រែហើយ ព្រះនង្គ័លត្រូវឈប់ជិតរោង មណ្ឌលទិសបូព ដើម្បីស្ដេចមាយចូលទៅថ្វាយបង្គំរួចចេញមកវិញ ។ បន្ទមកទៀតក្រុមបុរោហិតសូត្រអធិដ្ឋានប្រកាសផ្សង គោឧសភរាជ ដែលទឹមច្រត់ព្រះនង្គ័លនោះឱ្យស៊ីរបស់ប្រាំពីរមុខ ដែលរៀបដាក់លើតុប្រាក់ នៅពីមុខព្រះពន្លា ។ សូត្រចប់ហើយ ក៏ដឹកគោឱ្យស៊ីរបស់ទាំងប្រាំពីរមុខនោះគឺ :

**១** ទឹក : បើផឹកទឹក ទំនាយថា ទឹកធំ ឬភ្លៀងធ្លាក់ច្រើន ។

**២** គ្រាប់ស្រូវ : បើស៊ីស្រូវ ទំនាយថា បានផលស្រូវច្រើន ។

**៣** គ្រាប់សណ្ដែក: បើស៊ីសណ្ដែក បានផលសណ្ដែកបរិបូរណ៍។

**៤** គ្រាប់ល្ង: បើស៊ីល្ង បានផលច្រើន ។

**៥** គ្រាប់ពោត : បើស៊ីពោត បានផលពោតច្រើន ។

៥ ស្មៅ : បើស៊ីស្មៅ ទំនាយថាសត្វនឹងកើតជំងឺ ។

៦ ស្រា : បេផឹកស្រា ឆ្នាំនោះនឹងកើត មានមនុស្សពាល ចោរប្លន់អ្នកប្រមឹកស្រាច្រើន ។

**កំណត់សម្គាល់:** [១]ស្ដេចមាយ :គឺនាមទេវៈ ដើមរដូវ ឬ ជាអ្នកបើកផ្លូវ ។

[២] ព្រះមេហួ (ម៉ែហួ) :ពាក្យមេហួគឺកើតចេញពីពាក្យ បុរាណ គឺ ព្រះមេ។ ពាក្យហួជាពាក្យសៀម មានន័យថា ក្បាល ពោល គឺអ្នកដឹកនាំដែល មានមុខមាត់ អ្នកធំ ។ ម្យ៉ាងទៀតស្រូវអង្ករ ជានិមិត្តរូបនៃធម្មជាតិ និងរុក្ខជាតិជាប្រភព ដែលផ្ដល់ ជីវិតដល់មនុស្ស លោក។ ខ្មែរ និយមមេ ជាធំ ហេតុនេះបានជាខ្មែរបុរាណចាត់ទុក ស្រូវអង្ករជាធំ ឬ ជាមេ ឬជាម្ដាយ ។ ពេលភ្ជួរ អ្នកតំណាង ឬស្រីដែលបាចស្រូវ ជានិមិត្តរូបព្រះធរណី ឬព្រះនាងគង្ហីងដែលជាម្ដាយនោះ មិនគ្រាន់តែធ្វើឱ្យ រុក្ខជាតិដុះដាលប៉ុណ្ណោះទេ ថែមទាំងទទួលយកសពរបស់ខ្លួននិងសម្រាប់ធ្វើឱ្យរស់ឡើងវិញនូវរដូវ ក្រោយៗទៀត គឺមួយរដូវទៅមួយរដូវដូច ជីវិតកើតស្លាប់ៗ ។ ធម្មជាតិមានការប្រែ ប្រួលជានិច្ចដែលជាហេតុឱ្យខ្មែរបុរាណសន្និដ្ឋានដូចពោលខាងលើ។



Photos Pascal

ពិធីផ្សង គោឧសភរាជ

# តាំងគោក



ឈើឆ្កាងដីមរណៈសាក្សី តាំងគោក

ដី មរណៈសាក្សី... រហូតដល់ ១៩៨០ ក្នុងប្រទេសកម្ពុជា មរណៈសាក្សីបានបង្ហាញភាពស្មោះស្មគ្ររបស់ខ្លួនដើរតាមគំរូព្រះ យេស៊ូគ្រិស្ត ជាព្រះជាម្ចាស់ដោយសុខចិត្តស៊ូទ្រាំនឹងទារុណកម្ម និងទុក្ខវេទនាគ្រប់បែបយ៉ាង រហូតដល់ស្លាប់ ។

អ្នកធ្វើជាបន្ទាល់សាក្សីទាំងនេះ មានគ្រិស្តរិស័ទ ប្រុស ស្រី ក្មេង ចាស់ រួមមានទាំងគ្រហស្ថ លោកបូជាចារ្យ ដូនជី អ្នកបួស ព្រមទាំងលោកអភិបាលពីរអង្គផងដែរ ។ មរណៈសាក្សី ភាគច្រើនជាជនជាតិខ្មែរ តែក៏មានជនជាតិដទៃទៀតដែរ (វៀតណាម អឺរ៉ុប ជាដើម)។ មរណៈសាក្សី នៅប្រទេសកម្ពុជា បានពលីជីវិតដោយរបៀបប្លែកៗពីគ្នា និងតាមទីកន្លែងខុសៗគ្នា នេះជាមូលហេតុដែលយើងមិនអាចដឹងបានទីកន្លែងស្លាប់ឬផ្នូររបស់គេទាំងនោះឡើយ។ ដូច្នេះហើយ បានជាព្រះសហគមន៍កំណត់យកកន្លែងមួយធ្វើជាទីរំលឹកមរណៈសាក្សីទាំងនោះ ហើយគេបានពេញចិត្តជ្រើសរើសយកភូមិ "តាំងគោក" ដែលមានអត្ថប្រយោជន៍ប្រសើរបំផុតទាំងផ្នែកទីតាំង ភូមិសាស្ត្រ និងប្រវត្តិសាស្ត្រ។ តាំងគោក ជាភូមិមួយឋិតនៅក្នុងឃុំស្រយោង ស្រុក បារ៉ាយ ខេត្ត កំពង់ធំ។ ទៅទីនោះ គេត្រូវធ្វើដំណើរតាមផ្លូវជាតិ លេខ៦ ដោយឆ្លងកាត់ព្រែកលាភ (ឆ្លងស្ពានជ្រោយចង្វាទៅទិសខាងកើត) ទៅកាន់ស្គន់ រួចបត់ឆ្វេងទៅទីរួមខេត្តកំពង់ធំ ហើយដែលមានចម្ងាយប្រមាណ ២០ គ.ម ពីស្គន់។ ស្គន់ ជាចំណុចប្រសព្វជិតជាងគេបំផុតរវាង ភូមិភាគទាំងបីរបស់ព្រះសហគមន៍-កម្ពុជាគឺ : ភូមិភាគភ្នំពេញ ភូមិភាគបាត់ដំបង និងភូមិភាគកំពង់ចាម ។

សម័យ ប៉ុលពត-ខ្មែរក្រហមតំបន់តាំងគោក បានប្រមូលផ្តុំគ្រិស្តបរិស័ទជាច្រើនមកពីទីក្រុងភ្នំពេញ និងកំពង់ធំ ដែលបានទទួលរងទុក្ខរងទោសយ៉ាងវេទនាបំផុតដោយត្រូវបង្ខំឱ្យធ្វើការជាទម្ងន់ ហើយត្រូវស្លាប់ ដោយអត់ឃ្លាន ជំងឺ ភាគច្រើនគឺយកទៅសម្លាប់ ដោយចោទប្រកាន់ថាជាគេញសេអ៊ីអា យួន ជាប្រតិកិរិយាឬក្បត់អង្គការ ។ល។ ដោយឡែកការអធិដ្ឋាន ដោយសម្ងាត់របស់គ្រិស្តបរិស័ទ ក៏ត្រូវបានតាមដាន និងយកទៅសម្លាប់ផងដែរ។ ជាពិសេសលោកអភិបាល យ៉ូសែប សាឡាស់ក៏ត្រូវបាន ស្លាប់ ដោយបង្ខំឱ្យធ្វើការជាទម្ងន់និងអត់អា ហារ នៅក្នុងវត្តថ្លា ។

ហើយ ដីមួយកន្លែងនៅក្បែរវត្ត "ថ្លា" នេះបានទទួលការអនុញ្ញាត ឱ្យកសាងសាលាប្រជុំ ដែលនៅកណ្តាលកូនស្រែ មានតម្កល់ព្រះឈើឆ្កាងមួយធ្វើអំពីដែក ដោយនៅចំកណ្តោលព្រះឈើឆ្កាង មានរំលេចពាក្យ "ឆ្នាំព្រះមហាករុណាទិគុណ" ។

ក្នុងការប្រារព្ធ បើកពិធីរំលឹកមរណៈសាក្សី នៅថ្ងៃអាទិត្យទី ៧ ខែ ឧសភា ឆ្នាំ ២០០០វេលាម៉ោង ៩:៣០) ព្រះសហគមន៍ទីមួយៗ បានយកដីពីកន្លែងដែលមរណៈសាក្សីទទួលរងរុក្ខទោស ឬពលីជីវិតយកមកបាចក្នុងស្រែព្រះឈើឆ្កាង ដើម្បីទុកជានិមិត្តរូបនៃការរំលាយបញ្ចូលគ្នា ដីមរណៈសាក្សី និងដីព្រះឈើឆ្កាង។ បន្ទាប់មក ធ្វើពិធីប្រសិទ្ធិព្រះកាយ និងព្រះលោហិតព្រះយេស៊ូគ្រិស្ត ជាព្រះជាម្ចាស់ ។

ចុងក្រោយ គឺពិធី "សាបស្រូវពូជ" ទៅក្នុងដីលានមរណៈសាក្សី ដែលប្រែក្លាយទៅជាដីនៃសេចក្តីសង្ឃឹម ។

នៅថ្ងៃ ខែដដែលនេះជារៀងរាល់ឆ្នាំ ព្រះសហគមន៍ មិនភ្លេចនឹងនាំគ្នាទៅបូជនីយដ្ឋាន(កន្លែងដែលគេគោរពបូជា)ដើម្បីស្មឹងស្មាធិ៍ អធិដ្ឋាន ធ្វើអភិបូជា និងក៏ដើម្បីរំឮកប្រវត្តិ និងស្នាដៃរបស់មរណៈសាក្សី ដែលពោរពេញដោយបេះដូង និងគំរូរបស់ព្រះយេស៊ូគ្រិស្តដែលជាអំណោយទានព្រះជាម្ចាស់ប្រទានឱ្យដល់អស់លោកអ្នកទាំងឡាយនោះផងដែរ។



អត្តសញ្ញាព្រះកាយ និងព្រះលោហិត

## ព្រះបន្ទូលផ្តល់ជីវិត

ដ៏លើសលប់ ជាព្រះអំណោយទានដ៏ប្រសើរឧត្តមបំផុត ដែលមិនអាចកាត់ថ្លៃបាន ។ ព្រះយេស៊ូគង់នៅកណ្តាលចំណោមសាវ័ក ព្រះអង្គថែមទាំងលាងជើងឱ្យពួកគេទៀតផង។ ដូច្នេះ ពិធីលាងជើងរបស់ព្រះយេស៊ូ បញ្ជាក់អត្ថន័យទាំងមូល ដែលមានចែងក្នុងគម្ពីរលោកលូកា " ដ្បិតអ្នកណាមានឋានៈទាបជាងគេ ក្នុងចំណោមអ្នករាល់គ្នា គឺអ្នកនោះហើយជាអ្នកធំជាងគេ " លូកា ៩.៤៦ ។ ក្នុងរដូវបុណ្យចម្លងនេះ ចូរយើងទាំងអស់គ្នាចងចាំការប្រៀនប្រដៅរបស់ព្រះយេស៊ូចំពោះយើងម្នាក់ៗ ។

សាវ័កព្រះយេស៊ូ មិនយល់ពីអត្ថន័យនេះទេ គេនៅតែជាប់ចិត្តនឹងរបៀបរស់នៅតាមរបៀបលោកិយ ដោយផ្តល់អាទិភាពទៅលើអំណាច កិត្តិយស កេរ្តិ៍ឈ្មោះល្បីល្បាញក្នុងសង្គម ។ ប៉ុន្តែ ព្រះយេស៊ូយាងមកក្នុងលោកនេះ ដើម្បីបង្កើតពិភពលោកថ្មីមួយ សហគមន៍ថ្មីមួយ ត្រូវដឹកនាំតាមរបៀបថ្មីមួយ គឺសេចក្តីស្រឡាញ់ ។

ព្រះយេស៊ូ ជាព្រះជាម្ចាស់និងជាព្រះគ្រូ។ ព្រះអង្គ សព្វព្រះហឫទ័យលាងជើងឱ្យពួកសាវ័ករបស់ព្រះអង្គ (តាមច្បាប់ដែលមានកត់ត្រាទុកក្នុងគម្ពីរ-ជនជាតិអ៊ីស្រាអែលគ្មានសិទ្ធិនឹងប្រើជនជាតិអ៊ីស្រាអែលដូចគ្នាឱ្យលាងជើងខ្លួនទេ គឺត្រូវប្រើតែទាសករសាសន៍ដទៃតែប៉ុណ្ណោះ)។ យើងទាំងអស់គ្នា ក៏ដូច្នេះដែរ បើយើងចង់ដើរតាមព្រះយេស៊ូហើយបើយើងមានឋានៈតួនាទីខ្ពង់ខ្ពស់ក្នុងសង្គមថែមទៀតនោះ គឺយើងត្រូវបានព្រះជាម្ចាស់ត្រាស់ហៅឱ្យបម្រើអ្នកជិតខាងយើងតាមគំរូរបស់ព្រះយេស៊ូ ។

**" ក្នុងចំណោមអ្នករាល់គ្នា អ្នកដែលធំជាងគេហើយអ្នកដែលដឹកនាំគេ ត្រូវបម្រើគេ "**: នេះជាគំនិតមួយ ជារបៀបមួយរបស់ព្រះយេស៊ូជារបៀបដែលខុសប្លែកពីគំនិតមនុស្សលោក ។ តើធ្វើដូចម្តេច ឱ្យយល់ពីគំនិតនេះបាន ? ចូរយើងចងចាំ របៀបរស់នៅរបស់គ្រិស្តបរិស័ទ គឺគ្រប់យ៉ាងត្រូវប្រព្រឹត្តឡើងដោយមាន សេចក្តីស្រឡាញ់ ។

សេចក្តីស្រឡាញ់ នាំយើងឱ្យចេះនៅខាងក្រោយ គេបង្អស់ និងដាក់ខ្លួនជាអ្នកតូចតាចដូចឪពុកដាក់ខ្លួនប្រឡែងលេងជាមួយកូនឬជួយណែនាំកូនឱ្យធ្វើលំហាត់ដែលសាលារៀនដាក់ឱ្យធ្វើនៅផ្ទះ ។

ហេតុអ្វី យើងភ្លេចនឹកគិតដល់ "សុភមង្គល" របស់ដូនជី តេរេសា នៅកាល់គូតា ។ ដូនជីតែងតែឱនកាយបន្ទាបខ្លួនទៅក្បែរអ្នកជំងឺដែលហៀបនឹងផុតដង្ហើម-តើដូនជីបានធ្វើអ្វីចំពោះអ្នកជំងឺតូចតាចកំសត់ទុរគតទាំងនោះ?

" ដាក់ខ្លួនជាអ្នកតូចតាច " នៅចំពោះអ្នកដទៃ តើត្រូវធ្វើយ៉ាងដូចម្តេច? គឺជារបៀបដែលយើងត្រូវខិតខំ ចូលឱ្យជ្រៅទៅក្នុងជម្រៅដួងចិត្តរបស់គេ រហូតដល់អាចចែករំលែកទុក្ខកង្វល់ ការលំបាក ឬចំណង់ចំណូលចិត្តរបស់គេ ទោះបីអ្នកដែលស្ថិតនៅចំពោះមុខយើង គ្មានអត្ថន័យអ្វីសោះក៏ដោយ។ ប៉ុន្តែ ផ្ទុយទៅវិញ យើងបានវេញបញ្ចូលជីវិតយើងនៅក្នុងជីវិតរបស់គេ ។

ហេតុអ្វី បានជាយើងត្រូវដាក់ខ្លួនជាអ្នកតូចតាចចំពោះមនុស្សគ្រប់រូបដូច្នេះ ? នេះមិនមែនជាការប្រៀបធៀប រវាងមនុស្សពីរនាក់នោះទេ ប៉ុន្តែ ជារបៀបប្រុងប្រយ័ត្នមួយ ព្រោះបើយើងមិនធ្វើការត្រួតពិនិត្យទៅលើខ្លួនយើងទេ ពេលនោះ យើងមិនខុសអ្វីពីប៉េងប៉ោង ដែលត្រៀមខ្លួនហោះទៅលើនិងនឹកស្មានថា ខ្លួនល្អប្រសើរជាងអ្នកដទៃទាំងអស់ ។ " ក្នុងចំណោមអ្នករាល់គ្នា អ្នកដែលធំជាងគេ ត្រូវធ្វើតូចជាងគេហើយ អ្នកដែលដឹកនាំគេត្រូវបម្រើគេ" ចូរយើងរស់នៅជាមួយ "អ្នកដទៃ " កុំរស់នៅសម្លឹងមើលតែខ្លួនឯង គិតតែពីខ្លួនឯងចាប់អារម្មណ៍ខ្វល់ខ្វាយតែពីខ្លួនឯង បម្រើតែខ្លួនឯង ..សរុប




Illustrations CCCC

សេចក្តីទៅគឺវិលវល់ជុំវិញតែខ្លួនឯង ។

ចូរយើង បំភ្លេចខ្លួនយើងចោលខ្លះៗដើម្បីកុំឱ្យយើងលង់ខ្លួនជ្រៅពេក។ ចូរយើង ដាក់ខ្លួនរស់នៅជាមួយអ្នកផងទាំងពួង ដាក់ខ្លួនជាមនុស្សម្នាក់ក្នុងចំណោមបងប្អូនរបស់យើង ហើយណែនាំខ្លួនយើងឱ្យទៅមុខ និងជួយខ្លួនយើងឱ្យចេញផុតពីទុក្ខកង្វល់ ពីការលំបាកឈឺចាប់ ពីភាពស្មុគ្រស្មាញ ច្របូកច្របល់ពីភាពពិការខ្វិនខ្វង់របស់ខ្លួន... មានន័យថាយើងរំដោះខ្លួនឱ្យចេញផុតពីការគិត តែខ្លួនឯងហើយឈានទៅរកព្រះជាម្ចាស់ ឈានទៅកាន់បងប្អូនដែលនៅជុំវិញខ្លួនយើង។ ដូច្នេះ ដោយមានការគាំទ្រពីខ្លួនយើងៗនឹងឃើញអត្ថន័យដ៏ពេញលេញនៃជីវិត និងសុភមង្គល។ នៅក្នុងស្ថាប័ននយោបាយ និងរដ្ឋអំណាចអ្នកដឹកនាំទាំងអស់អាចបង្កើនការទទួលខុសត្រូវមួយដែលគិតគូរនិងបម្រើផលប្រយោជន៍រួម ដូចជាផលប្រយោជន៍របស់យុវជន កន្លែងស្នាក់នៅស្វែងរកការងារធ្វើ ស្វែងរកការសិក្សា ហើយត្រូវការជាចាំបាច់ មធ្យោបាយផ្សេងៗដូចជា: ដើម្បីមានការងារធ្វើក្នុងក្រុមហ៊ុនសហគ្រាស និងទីកន្លែងមួយសមរម្យតាមលទ្ធភាព និងសមត្ថភាពសេដ្ឋកិច្ចរបស់គេ។ តាំងពីពេលយើងភ្ញាក់ពីដំណេក ពីព្រឹករហូតដល់យើងចូលនិទ្រាពេលយប់ ទាំងនៅផ្ទះ កន្លែងធ្វើការសាលារៀន តាមផ្លូវ យើងតែងតែមានឱកាសបម្រើបងប្អូនជានិច្ច។ ហើយយើងក៏មានឱកាសអរគុណបងប្អូន យើងដែលបានជួយធុរៈយើងវិញដូចគ្នា ដែរ។

ចូរយើងប្រព្រឹត្តអ្វីៗគ្រប់យ៉ាងចំពោះបងប្អូន ដើម្បីព្រះយេស៊ូហើយត្រូវស្រឡាញ់បងប្អូនទាំងអស់ ដូចៗគ្នាមិនគួឱ្យមានការធ្វេសប្រហែសឬរំលងអ្នកណាម្នាក់ឡើយ។ ដោយការបន្ទាបខ្លួន ធ្វើជាអ្នកតូចតាច ជាអ្នកបម្រើបងប្អូនដោយគ្មានការប្រកាន់ ឋានៈ វណ្ណៈ សម្បុរ ជាតិសាសន៍ គឺពេលនោះហើយ ដែលយើងជា "អ្នកធំជាងគេ" ។

## ទិវាពលកម្មអន្តរ ជាតិ

អន្តរជាតិ: សហរដ្ឋអាមេរិក នៅចុងសតវត្ស ទី១៩ នៅញូយ៉ក គេយក ថ្ងៃទី១ ឧសភា ថាជាថ្ងៃផ្លាស់ប្តូរ (The Moving Day) ។ គឺថ្ងៃនេះហើយ ដែលសេចក្តីសម្រេចផ្នែកសេដ្ឋកិច្ចក៏ដូចជាកិច្ចសន្យាការងារ ចាប់ផ្តើមមានអានុភាព ។

ឆ្នាំ១៨៨៤ នៅឈីកាហ្គូសមាជសហជីពកម្មករអាមេរិកបានសម្រេចឱ្យធ្វើការងារតែប្រាំបី ៨ ម៉ោង ចាប់តាំងពីថ្ងៃទី១ឧសភាឆ្នាំ១៨៨៦នេះតទៅ។ ដើម្បីនឹងឱ្យបរិបាលតា(ម្ចាស់រោងចក្រ ពួកអ្នកត្រួតត្រា ឬពួកអ្នកធំ) និងរដ្ឋាភិបាល ដែលនៅតែរួញរាចំពោះសំណើនេះ សហជីពកម្មករ ផ្សេងៗបានរៀបចំកូដកម្ម និងបាតុកម្ម។ អស់ពេលជាច្រើនឆ្នាំ បន្ទាប់ពីការរំលឹកការតស៊ូថ្ងៃ ១ ឧសភា មកថ្ងៃនេះក៏ក្លាយជាថ្ងៃ ទិវាពលកម្មអន្តរជាតិរៀងរហូតមក។

នៅប្រទេសបារាំង ក្រោមការជម្រុញរបស់លោក រ៉ាយម៉ុងឡាវីញសមាជពួកសង្គមនិយមអន្តរជាតិនៅប៉ារីស បានសម្រេចតវ៉ាដើម្បីឱ្យកម្មករបានធ្វើការក្នុងមួយថ្ងៃប្រាំបី(៨)ម៉ោង កូដកម្មជាច្រើន បានធ្វើជាបន្តបន្ទាប់ទាំងនៅក្នុងបារាំង និងក្នុងបណ្តាប្រទេស នៅអឺរ៉ុប មានដូចជា: អាល្លឺម៉ង់ អ៊ីតាលី បែលហ្ស៊ិក ស្វីស ព័រទុយហ្គាល់ អេស្ប៉ាញ អង់គ្លេស ស៊ុយអ៊ែត និងប្រទេសផ្សេងៗ ទៀត។ ហើយរហូតមកដល់ឆ្នាំ១៩៤១ ទើបមានការទទួលស្គាល់ ថ្ងៃទី១ ឧសភា ថាជាថ្ងៃ បុណ្យការងារ។

កម្ពុជា : ប្រទេសកម្ពុជាបានចាប់ផ្តើមធ្វើច្បាប់ការងារចាប់ពីពេលដែលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ។ គេសង្កេតឃើញថាច្បាប់ជាច្រើនព្រម ទាំងច្បាប់ការងារ-របស់ប្រទេសកម្ពុជាហាក់បីដូចជាយកគំរូតាមច្បាប់បារាំង។ ហើយច្បាប់ការងារក្នុង ទសវត្សរ៍ ១៩៧០ បានក្លាយជាគំរូសម្រាប់គេសសេរច្បាប់ការងារក្នុងទសវត្សរ៍១៩៨០ ដែរ ។ ច្បាប់ការងារ ឆ្នាំ១៩៩២ បានហាមឃាត់លើការងារបង្ខំ បានបង្កើតឡើងរយៈពេល និងលក្ខខ័ណ្ឌពិស្តារស្តីពីការជួលធ្វើការងារ បានផ្តល់ជារួមសិទ្ធិប្រកែកតវ៉ាខ្លះ តែសហជីពមិនមានសិទ្ធិពិសេសធ្វើកូដកម្មឡើយ។ ហើយច្បាប់នេះ មិនមានប្រព័ន្ធពិស្តារសម្រាប់គ្រប់គ្រងច្បាប់ការងារ ឬដោះស្រាយជម្លោះការងារទេ ព្រោះវាមិនមានបទបញ្ញត្តិទណ្ឌកម្មពិស្តារ ។

ច្បាប់នេះត្រូវបានអនុម័តនៅខែ កញ្ញា ឆ្នាំ ១៩៩៣។ ច្បាប់ការ-ងារ ឆ្នាំ១៩៩៧: បានត្រូវសភាជាតិកម្ពុជា អនុម័តនៅខែមករា ឆ្នាំ១៩៩៧ ហើយ ដែលចូលជាធរមានថ្ងៃទី៣ មេសា ឆ្នាំ ១៩៩៧ ។ ច្បាប់ការងារក្រោយនេះ បានចែងពីទំនាក់ទំនងរវាងកម្មករ និងនិយោជក (អ្នកគ្រប់គ្រង ឬថៅកែ) និងអ្នកធ្វើការងារគ្រប់ប្រភេទទាំងផ្នែកឧស្សាហកម្ម កសិកម្ម សិប្បកម្ម សេវាកម្ម ឬដឹកជញ្ជូន ។ល។



## ជីវិតកំព្រា

\- ជីវិតកំព្រានាសព្វថ្ងៃ ប្រឹងគ្មានសំចៃខំខ្ទីឃ្មាត
ព្យាយាមសិក្សាឥតរវាទ ចៀសឱ្យចាកឃ្លាតពីភពខ្លៅ ។
\- ជីវិតកំព្រារងាក្រៃ រស់ស្មើនឹងថៃក្រោមមេឃា
ស៊ូយ៉ាងស្រមោចសឹងមិនធារ ទោះយប់សន្ធិយាក៏មិនគិត ។
\- ជីវិតកំព្រារងាណាស់ វាសនាប្តូរផ្លាស់ប្រៀបពពក
រសាត់រសាច[១] បាចទៅមក ដូចទឹករលករគឹងរគោង[២] ។
\- ជីវិតកំព្រាហ៊ានតតាំង តស៊ូព្រោះឆ្នាំងយ៉ាងអំណត់
ចុះទឹកហាលថ្ងៃឥតក្រែង[៣] ហត់ ទោះខ្សត់[៤] ខ្ទីឃ្មាត[៥] ទ្រត្រួសារ ។
\- ជីវិតកំព្រារងរក្សា សម្បត្តិខេមរាទុកជាកេរ្តិ៍
ដំណែលតម្កើងគិតគ្មាន់គ្នេរ[៦] រិះរេឱ្យជាតិបានរុងរឿង ។
\- ជីវិតកំព្រាពេញចំណេះ កុំខ្លាំង[៧] តម្រិះនិងគ្នាគ្នី
ចូរចាំឱ្យស្ទាត់ក្នុងជីវី ជាយាន[៨] ទាំងពីរជួយផុតគ្រោះ ។
\- ជីវិតកំព្រានាឥឡូវ ត្រូវចេះរកផ្លូវដោយចិត្តស្មោះ
មិនត្រូវពឹងពាក់លួចប្លន់សោះ នាំឱ្យអាប់យសក្នុងសង្គម ។
\- រដូវដើមឆ្នាំដាំបន្លែ ស្រោចទឹកធួនថែដោយខិតខំ
ពាក្យម៉ែពាក្យឪយកជាធំ កុំតបចាស់ទុំដោយវោហា[៩] ។
\- ជីវិតកំព្រាមិនត្រូវឃ្លាត បោះបង់ចោលញាតិសំដីក្លា
ប្រើពាក្យចោលម្សៀតឥតបានការ មាតាបិតាជួបវិបត្តិ ។
\- ជីវិតកំព្រាត្រូវលាចាក កុំឱ្យឮពាក្យរោគព្យាធា
ពិភពសព្វថ្ងៃរងវេទនា ព្រោះតែរោគាស្លាប់គ្មានសល់ ។
\- កញ្ញាអាភៀននិងស្រីស្រា ប៉ះវាកាលណាមានអំពល់
ប្រល័យជីវិតពុំគិតដល់ មានក្រសោះសល់[១០] ស្លាប់ដូចគ្នា ។

***តែងដោយៈ លោក អិល ឈិញ និស្សិត ឆ្នាំទី ៤ ផ្នែកអគ្គីសនី នៃសកលវិទ្យាល័យ ន័រតុន***

## សេចក្តីជូនដំណឹង




CCCC បានធ្វើសៀវភៅសំរាប់ព្រះសហគមន៍ ។ឥឡូវមានដាក់ឱ្យជាវសៀវភៅ □ **ការរៀបចំខ្លួនទទួលព្រះកាយព្រះគ្រិស ” និង សៀវភៅផ្សេងទៀត**បើបងប្អូន ត្រូវការសូមទាក់ទងមក CCCC **អាស័យដ្ឋានៈ ផ្ទះ១០១ សង្កាត់ បឹងត្របែក ខ័ណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ : ០២៣ ២១១ ២៥៣**




**មានលក់ ហើយ ! មានលក់ ហើយ !**
កាសែត និងស៊ីឌីចំរៀងសម្រាប់អភិបូជា ចាប់ពីថ្ងៃនេះតទៅ នៅព្រះវិហារផ្សារតូច ឬទាក់ទងទូរស័ព្ទៈ ០២៣)២២៤-១២០

## គួរយល់ដឹង មានអ្វី?

**អាអេហ្វប៉េ-យ៉ូហាណេស្ប៊ឺក១៧/០៥/០៤:**


*ប្រធានាធិបតី ម៉ង់ដឺ ឡា*

បាល់ទាត់-វិរៈ បុរសស្វាគមក្រុមស្នើសុំ ធ្វើពានពិភពលោកបាល់ទាត់ ២០១០នៅអាហ្វ្រិកខាងត្បូង។ ក្រុមនេះបានមកដល់ប្រទេសគេវិញ (អាហ្វ្រិកខាងត្បូង) នៅព្រឹកព្រលឹមថ្ងៃអាទិត្យទី ១៦/០៥/០៤ ដោយមានការស្វាគមន៍មិនសម្ងែងមួយពីវិរៈបុរសរបស់គេ នៅពេលប្រទេសនេះអបអរសាទរការទទួលធ្វើជាម្ចាស់ផ្ទះកីឡាបាល់ទាត់ពិភព លោកឆ្នាំ ២០១០ ខាងមុខនេះ បន្ទាប់ពីប្រទេសអាលឺមង់ឆ្នាំ២០០៦។ **ប៊ីប៊ីស៊ី-កីឡាៈ ច័ន្ទ ៣/៣/០៤:** បាលទាត់ៈ ក្រោមចំណងជើងថាៈ ”*បេកខេមឈ្មោះលើគេ ក្នុងបញ្ជីអ្នកមាននៃក្រុមកីឡាបាលទាត់* ”: ដាវីឌ បេខេមៈ ប្រធានក្រុមកីឡាបាល ទាត់អង់គ្លេស មានប្រាក់ ១៥ លានផោន (១ ផោន= ១,៨ ដុល្លារ អាមេរិក) នៅឆ្នាំមុន។ ទស្សនាវដ្ដីបារាំងនិយាយថាៈ រាលម៉ាឌ្រីដបាន ឱ្យតម្លៃខ្លួនបេកខេម ៤,៤ លានផោន ក្នុងនោះមានទាំងប្រាក់បន្ថែម នៅពេលបេកខេមរវល់មិនបានទៅហាត់ ផងដែរ ។ បន្ទាប់មក គឺៈ-រ៉ូណាដូកីឡាករ(រាលម៉ាឌ្រីដ)មានប្រាក់១១
\- ហ្សីឌីន ហ្សីដាន កីឡាករ រាលម៉ាឌ្រីដ មានប្រាក់ ៩,៤ លានផោន
\-អ្នកប្រហារ(អ្នកទាត់បញ្ចូលទីដ៏ប៉ិនប្រសប់)មីខារអ៊ែល អូវីន កីឡាករក្រុមលីវើពូល(អង់គ្លេស)ជាអ្នកលេងដែលទទួលតម្លៃខ្ពស់ ណាស់ដែរ មានទឹកប្រាក់ ៦,១ លានផោន។ ***ទេព ផានី***

# វិធីទាំង៧ក្នុងការអធិដ្ឋាន

ដកស្រង់ចេញពីវីដេអូដែលមានឈ្មោះថា seven circle of prayer ដែលចេញផ្សាយ ដោយ CAHAYA SUARA RESOURCE CENTRE ពីទីក្រុងកូឡាឡាំពួរ ហើយបកប្រែជាភាសាខ្មែរ ដោយបងស្រី សង្វាត និង បងស្រី ថារីន ក្រុមគ្រួសារ ស្រឡាញ់ព្រះយេស៊ូឆ្កាង។ **តពីលេខមុន**




## ៧- ការទល់មុខ នឹងព្រះជាម្ចាស់

ក្នុងជំហានទី ៧ នេះអ្នកនឹងជួប ព្រះជាម្ចាស់ (ទល់មុខ) ព្រះជាម្ចាស់មានមុខ មាត់ជាមនុស្សក្នុងព្រះយេស៊ូគ្រិស្តជាអម្ចាស់ ព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់ ជាព្រះបន្ទូល របស់ព្រះជាម្ចាស់ ដែលមានសាច់ឈាមដូច មនុស្ស ។ ដោយសារព្រះយេស៊ូ មនុស្សមិន នៅឆ្ងាយពីព្រះជាម្ចាស់ឡើយ។ នៅក្នុងព្រះ រាជ្យព្រះជាម្ចាស់ គ្មាននរណាមួយតូចជាងគេ គ្មានអ្នកទន់ខ្សោយជាងគេ គ្មាននរណាម្នាក់ ដែលគ្មានសារៈសំខាន់ ឬក៏ព្រះជាម្ចាស់មិន-ចាប់អារម្មណ៍នោះឡើយ ។ ព្រះជាម្ចាស់មាន ព្រះហឫទ័យមេត្តាចំពោះមនុស្សទាំងអស់។

ព្រះយេស៊ូ ជាព្រះជាម្ចាស់ដែល កំពុងយាងមករកយើង ព្រះអង្គសព្វព្រះទ័យ យាងមកយកកំណើតជាមនុស្សក្នុងចំណោម យើងទាំងអស់គ្នា។ទ្រង់ជ្រាបផងដែរថា ធ្វើជា មនុស្សដូចបងប្អូន មានន័យយ៉ាងណា? តាម រយៈព្រះយេស៊ូ ព្រះជាម្ចាស់បានសន្យានឹង បង្ហាញព្រះភ័ក្រ្ត ព្រះអង្គផ្ទាល់ ដោយទល់មុខ ជាមួយអស់បងប្អូនដែលបានរស់នៅដោយ សេចក្តីស្រឡាញ់។

ដូច្នេះ ក្នុងការអធិដ្ឋានរបស់បងប្អូន សូមអង្វរព្រះជាម្ចាស់ សូមទ្រង់បង្ហាញ ព្រះភ័ក្រ្តព្រះអង្គផ្ទាល់ក្នុងព្រះយេស៊ូ និងសូម អង្វរព្រះជាម្ចាស់ សូមកុំឱ្យបងប្អូនឃ្លាតឆ្ងាយ ពីព្រះអង្គពេលដែលទ្រង់យាងមក។ នេះ ជា ការមួយដែលជួបប្រទះដោយផ្ទាល់នៅក្នុង ដួងចិត្តរបស់បងប្អូនម្នាក់ៗ នៅក្នុងជំហានទី ៧នៃការអធិដ្ឋាននេះ។

ជួនកាល នៅពេល ដែលបងប្អូនកំពុងអធិដ្ឋាន ស្ងៀមស្ងាត់ដោយខ្លួនឯង រំពេច នោះបងប្អូននឹង ដឹងថា ការអធិដ្ឋាន មិនមែនជាភាពស្ងៀមស្ងាត់ទទេ ឬការ និយាយម្នាក់ឯងនោះឡើយ។ ប៉ុន្តែ វាជាការ សន្ទនារវាងបងប្អូន និងព្រះជាម្ចាស់ដែល យើងមិនបានស្គាល់ព្រះអង្គឡើយ។ ជួនកាល ព្រះអង្គបង្ហាញព្រះអង្គនៅ ពេលដែលបងប្អូន មិនបានគិតដល់ទ្រង់ ឬពេលបងប្អូនជាប់រវល់ នឹងការងារ ។

ព្រះជាម្ចាស់ក៏ដូចជាមិត្តភាព( ទំនាក់ ទំនងជាមួយអ្នកដទៃ) ដែលមាននៅជុំវិញ បងប្អូន។ ជួនកាល ព្រះជាម្ចាស់ទ្រង់បង្ហាញ ឱ្យយើងឃើញនៅពេលយើងនិយាយជា មួយមិត្តភក្តិ និងសហសេវិក។ ហើយព្រះអង្គ យាងមកនៅពេលដែលបងប្អូនទុក្ខចិត្តគ្នា ទៅវិញទៅមក និងនិយាយសេចក្តីពិត ។

ជួនកាល ទ្រង់គង់ជាមួយបងប្អូននៅ ពេលបងប្អូនធ្លាក់ទឹកចិត្ត និងមានអារម្មណ៍ ឯកោម្នាក់ឯង។ ព្រះជាម្ចាស់ ធ្លាប់បានទទួល អ្វីជាការបដិសេធ និងការក្បត់រួចទៅហើយ តាមរយៈព្រះយេស៊ូ។ ព្រះយេស៊ូ សព្វព្រះហឫទ័យទទួលទុក្ខលំបាកយ៉ាងធ្ងន់ធ្ងរ និងភាព ឯកោជំនួសយើង ហើយបានត្រាស់ហៅបងប្អូន និង ខ្ញុំចំឈ្មោះម្នាក់ៗ ទៀតផង។

ព្រះសហគមន៍ បានកើតឡើងដោយ ការរួបរួមគ្នារបស់មនុស្សរាប់លាននាក់ រួច បានបង្រួបបង្រួមឱ្យមនុស្សទាំងអស់ ដើម្បី លើកតម្កើង កោតសរសើរព្រះជាម្ចាស់ ដោយជួបជុំគ្នាក្នុងការអធិដ្ឋានដ៏សំខាន់មួយគឺ **"អភិបូជា"** ។ តាំងពីអតីតកាលរហូតដល់ បច្ចុប្បន្ន អភិបូជាគឺជាការជួបជុំគ្នាអធិដ្ឋាន របស់បងប្អូនអ្នកជឿ។ នៅក្នុងអភិបូជានេះ គេបានប្រើគ្រឿងឧបភោគបរិភោគក្នុង គ្រួសារ។ វាប្រារព្ធឡើងដោយៈ ប្រជាជនដែល មករួបរួមគ្នាអធិដ្ឋាន បើកដួងចិត្ត និងទុក្ខចិត្ត គ្នាទៅវិញទៅមក សេចក្តីស្រឡាញ់ ក្នុង អភិបូជាដែលរំលឹកដល់ ទុក្ខលំបាករបស់ព្រះ យេស៊ូ និងមនុស្សទាំងអស់ និងសេចក្តីសង្ឃឹម ដែលកើតចេញពីសេចក្តីទុក្ខ។

ក្នុងវិធីទី៧នេះ គេបានបង្រួមជា ចំនុចតែមួយគឺ មានសេចក្តីស្ងៀមស្ងាត់ ទីកន្លែង ពេលវេលា ទុក្ខលំបាក ការប៉ះស្ទាប កាស្តាប់ និងការជួបព្រះជាម្ចាស់ដោយទល់ មុខ និងទ្រង់ (នៅក្នុងដួងចិត្តរបស់បងប្អូន)។

**ចប់**



# សកម្មភាពយុវជនក្រុងព្រះសីហនុ



*ការជួយជួសជុល ផ្ទះអ្នកក្រីក្រ*

យុវជនយុវនារី ព្រះសហគមន៍ក្រុងព្រះសីហនុ ចំនួន៥៧នាក់បានជួបប្រជុំគ្នារៀបចំគម្រោងផែនការសកម្មភាពរបស់ពួកគេដូចខាងក្រោមនេះ :

ជារៀងរាល់ថ្ងៃអាទិត្យ ក្រោយពីអភិបូជា មានបើកថ្នាក់អប់រំជំនឿដែលចែកជាថ្នាក់សម្រាប់កុមារតូចៗ និងមនុស្សពេញវ័យ ដើម្បីឱ្យពួកគេបានយល់ដឹងពីតួនាទី ភារៈកិច្ចរបស់គេម្នាក់ៗចំពោះព្រះសហគមន៍ និងតួនាទីរបស់ព្រះសហគមន៍ត្រលប់ទៅវិញ ព្រមទាំងដាស់ស្មារតីគេក្នុងការត្រៀមខ្លួនក្លាយជា គ្រិស្តបរិស័ទ នៅពេលខាងមុខនេះ។ ក្រោយពីការអប់រំជំនឿ គេឆ្លៀតរៀបចំ កម្មវិធីបុណ្យ និងគម្រោងសម្រាប់អាទិត្យ បន្ទាប់ទៀត។ មិនតែប៉ុណ្ណោះ យុវជន-យុវនារីបានហាត់រៀនលេងហ្គីតា អ័ក្ស និងចំណេះដឹងទូទៅផងដែរ ។

គម្រោង ដែលពួកគេបានពិភាក្សា និងយកជាផ្លូវការដើម្បីអនុវត្តប្រចាំសប្តាហ៍ ក៏ដូចប្រចាំខែ និងឆ្នាំផងដែរ នោះគឺ:

-អាទិត្យទី ១ : ធ្វើពលកម្ម បោសសំអាត រៀបចំព្រះវិហារ ឬចុះទៅតាមភូមិ ដើម្បីជួសជុលផ្ទះអ្នកក្រីក្រ ។

-អាទិត្យទី ២ : ចុះទៅសួរសុខទុក្ខអ្នកជំងឺ និងអ្នកក្រីក្រ ។

-អាទិត្យទី ៣ : រៀនរួមគ្នាអំពីចំណេះដឹងទូទៅ ។

-អាទិត្យទី៤ : ទៅតាមភូមិ ដើម្បីសួរសុខទុក្ខកុមារ មានចែកស្កគ្រាប់នំចំណី ព្រមទាំងសៀវភៅជាពិសេសចំពោះកុមារក្រីក្រ។

នៅថ្ងៃ ខាងមុខ យុវជន យុវនារីនឹងមាន គម្រោងបើកមហាសន្និបាតយុវជននៅព្រះសហគមន៍ ដើម្បីចែករំលែកបទពិសោធន៍ការងារព្រះសហគមន៍ ក៏ដូចក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ម្យ៉ាង ការជួបជុំនេះអាចឱ្យពួកគេបានស្គាល់គ្នា



*យុវជនយុវនារី ព្រះសហគមន៍ក្រុងព្រះ សីហនុ*

**សម្គាល់ ទំព័រទី ៦ :** [1] រសាត់រសាចៈបែកខ្ញែក, [2] រគីងរគាងៈខ្ពស់ទាបៗ, [3] ក្រែងហត់ៈឥតខ្លាច, [4] ខ្សត់ៈទ័លក្រ, [5] ខ្មីឃ្មាតៈខំប្រឹង, [6] គិតគ្នាន់គ្នេរៈ រិះរេលៃលកមើល, [7] ខ្ជាំងៈចិត្តជាសត្រូវ, [8] យានមានពីរៈ គ្រឿងដឹកនាំមានយានគ្រួសារ និងយានសង្គម, [9] វោហារៈ ពាក្យពេចន៍, សំនួនសំដី [10] សោះសល់ៈ គ្មានសល់។

- ***អ្នកនាំសារ*** សូមថ្លែងអំណរគុណចំពោះ លោក ***អិល ឈិញ*** ដែលបានផ្ញើអត្ថបទកំណាព្យដ៏មានអត្ថន័យ និងបងប្អូនទាំងអស់ ដែលបាន សរសេរអត្ថបទមកកាន់***អ្នកនាំសារ***។
- ***អ្នកនាំសារ*** ក៏សូមអភ័យទោសរាល់កំហុសឆ្គងទាំងឡាយដែលបានកើតមាន (ដោយចេតនា និងអចេតនា ពិសេសអក្ខរាវិរុទ្ធ)។ យើងខ្ញុំ ទទួលស្វាគមន៍ជានិច្ចមតិយោបល់ ការរិះគន់ កែរតម្រូវ របស់បងប្អូន។ សូមបងប្អូនសរសេរសំបុត្រផ្ញើមក**ការិយាល័យ ព្រឹត្តិបត្រអ្នកនាំសារ : អាសយដ្ឋានផ្ទះ លេខ ២៥ ផ្លូវ ២៤២ បឹងព្រលិត ភ្នំពេញ ។ ប្រអប់សំបុត្រលេខ ១២៣ ភ្នំពេញ ទូរស័ព្ទ/ទូរសារ (០២៣) ២២៤ - ១២០** ឬ ផ្ញើតាមរយៈលោកបូជាចារ្យដែលទទួលខុសត្រូវតាមកន្លែងដែលបងប្អូនរស់នៅ។ ***សូមអរគុណ !***

**ក្រុមនិពន្ធ**
ទេព ផានី, គីម សំអាត
**រូបភាព :** គុយវិន , Pascal
**កុំព្យូទ័រ :** លី សុវណ្ណា
ការិល័យផ្សព្វផ្សាយពតិមានព្រះសហគមន៍កាតូលិក
Nº 25, st.242,Boeung Prolet
Tel: (023)224120
E-mail : csc@catholiccambodia.org
អភិបាលគ្រប់គ្រង
លោកអភិបាល អេមីល ដេតម្ប
អគ្គនាយក
លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ